ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០១៧

**សេចក្តីផ្តើម** :

នៅក្នុងខែមករានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:**

**១.មុខងារនីតិកម្ម:**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០៣លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន ០១លើក ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៩ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក របាយការណ៍ថវិការបស់ព្រឹទ្ធសភាឆ្នាំ២០១៦ និងគោលការណ៍បែងចែក និងប្រើប្រាស់ថវិការបស់ព្រឹទ្ធសភាឆ្នាំ២០១៧<br>- ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសិក្សាលើ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំវិសាមញ្ញព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល បម្រើភេសជ្ជៈ ផ្គត់ផ្គង់សម្ភារៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំចំនួន១១លើក មានអ្នកចូលរួមចំនួន៥៥៣នាក់<br>- ថតចម្លងឯកសារបានចំនួន១៧សំណើ អស់ក្រដាសចំនួន៣១,៤២៨សន្លឹក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗចំនួន៥២នាក់ និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នចំនួន១៣០នាក់<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446 E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| សេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់<br>- ប្រជុំគណៈកម្មការពិសេសស្តីពី ការរៀបចំសេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។ | ពីរាជរដ្ឋាភិបាល និងបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជ-ក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗចំនួន៤៣ច្បាប់<br>- បន្តធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា និងបញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បាននឹងកំពុងធ្វើជំនួយស្មារតីសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ និងស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន ០១ច្បាប់<br>- បានសិក្សាស្រាវជ្រាវ និងបកប្រែកិច្ចការសភានៃសាធារណរដ្ឋហ្វីលីពីន<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០៤ លើក និងរៀបចំប្រព័ន្ធសំឡេងចំនួន០៩លើក ថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មាន ចំនួន១២លើក<br>- បានបញ្ចូលឯកសារច្បាប់របស់ព្រឹទ្ធសភា នីតិកាលទី១ និងទី២ ក្នុងគេហទំព័រ E-library ព្រឹទ្ធសភា<br>- បានរៀបចំតបណ្តាញរូបភាព និងសំឡេងពីសាលប្រជុំពេញអង្គទៅកាន់វិទ្យុជាតិដោយផ្ទាល់ ។ |

## ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបានៈ<br>+ អញ្ជើញចុះតាមដានឈ្វេងយល់ពីការប្រែប្រួលក្រោយរៀបចំវេទិកាតាមបណ្តាខេត្តនីមួយៗក្នុងភូមិភាគទី៧ នៅខេត្ត | - ធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អមដំណើរសមាជិកព្រឹទ្ធសភា ចុះទៅសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ចំនួន១៥នាក់ |

| | |
|---|---|
| ព្រះសីហនុ កោះកុង និងខេត្តពោធិ៍សាត់ ។ | ស្មើនឹង០៣ច្បាប់<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១០នាក់ ស្មើនឹង០២លើក ។ |

**៣.មុខងារតំណាង** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាបាន៖<br>+ អញ្ជើញជាអធិបតី និងជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារការិយាល័យថ្មីរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន០១ខ្នង កម្ពស់៣ជាន់ ជាជំនួយរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនជូនដល់ព្រឹទ្ធសភាកម្ពុជា<br>+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ និងរំលែកទុក្ខព្រះសព **សម្តេចស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស** អតីតអនុប្រធានទី១ ព្រឹទ្ធសភា ព្រមទាំងចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីបូជាព្រះសព នៅវត្តបទុមវតី រាជធានីភ្នំពេញ<br>+ អញ្ជើញជាអធិបតីប្រទានភ្លើងបូជាសព និងចូលរួមរំលែកទុក្ខគ្រួសារសពចំនួន០៤លើក នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ជូន ឯកឧត្តម ប្រធានាធិបតីនៃសាធារណរដ្ឋសិង្ហបុរី និងលោកជំទាវ នៅក្នុងព្រះបរមរាជវាំង | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាអធិបតី ក្នុងពិធីផ្លូវការផ្សេងៗ សរុបចំនួន៣៩២លើក<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា ការចុះតាមដានឈ្វេងយល់លទ្ធផលក្រោយការរៀបចំវេទិកា និងកម្មវិធីផ្សេងៗ នៅខេត្តត្បូងឃ្មុំ សៀមរាប បាត់ដំបង ព្រះសីហនុ កោះកុង ពោធិ៍សាត់ ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងខេត្តកំពង់ធំ<br>- បានសហការរៀបចំ និងចាត់ចែងពិធីគោរពវិញ្ញាណក្ខន្ធសពចំនួន០២លើក<br>- បានចុះសួរសុខទុក្ខនិវត្តន៍ជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៦១នាក់ ស្មើនឹង៤២ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន១០នាក់ ស្មើនឹង១០ច្បាប់ |

| | |
|---|---|
| + អញ្ជើញចូលជួបប្រជុំជាមួយគណៈអភិបាលក្រុងច្បារមន និងចៅសង្កាត់ទាំង៥ ចំណុះក្រុង ដើម្បីស្តាប់របាយការណ៍ស្តីពីសភាពការណ៍ទូទៅរបស់ក្រុង សង្កាត់នីមួយៗចំណុះក្រុង និងស្តាប់របាយការណ៍ចុះឈ្មោះបោះឆ្នោតនាពេលកន្លងមកនៅខេត្តកំពង់ស្ពឺ<br>+ អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋាន ភូមិ សង្កាត់ និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ និងខេត្តកំពត<br>+ ចូលរួមពិធីសូត្រមន្តប្រោះព្រំ សុំសេចក្តីសុខសេចក្តីចម្រើនសម្រាប់អគារការិយាល័យថ្មីរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា<br>+ អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅក្រុងតាខ្មៅ ខេត្តកណ្តាល និងខេត្តពោធិ៍សាត់<br>+ អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អគារសិក្សា០១ខ្នង នៅខេត្តកណ្តាល<br>+ អញ្ជើញចែកអំណោយ និងជប់លៀងជូនប្រជាពលរដ្ឋអបអរសាទរបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល២០១៧ នៅខេត្តពោធិ៍សាត់<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបលើកទី៣៨ នៃទិវាជ័យជំនះ៧មករា នៅទីស្នាក់ការកណ្តាលគណបក្សប្រជាជនកម្ពុជា | - ថតចម្លងឯកសារចំនួន១៣សំណើ អស់ក្រដាសចំនួន២០,៣៦១សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូន និងថវិកាសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងទាំង៨ភូមិភាគចំនួន១៥០នាក់ ស្មើនឹង២៦លើក និងទូទាត់ថ្លៃជួសជុលរថយន្តចំនួន៣៣លើក<br>- ទទួលលិខិតចូលចំនួន១,៥៩៣ច្បាប់ និងបញ្ជូនលិខិតចេញចំនួន២៧០ច្បាប់<br>- ផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗសរុបចំនួន៥៩លើក<br>- បានប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង ដើម្បីការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងពិធីផ្សេងៗ ចំនួន៦៥នាក់ ស្មើនឹង០៣លើក<br>- ផ្តល់រូបថតចំនួន១,៥៨០សន្លឹក និងអត្ថបទសារព័ត៌មានចំនួន៤៦អត្ថបទ ជូនខុទ្ទកាល័យ និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន៣១៧នាក់ ធ្វើប័ណ្ណសមាជិកចំនួន១១រូប ខ្ចីសៀវភៅចំនួន៨១ក្បាល និងសងវិញចំនួន៨៥ក្បាល<br>- សម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សាចំនួន០១លើក របស់លោកគ្រូ អ្នកគ្រូ សិស្ស និងនិស្សិត មកពីសាកលវិទ្យាល័យនានា |

| | |
|---|---|
| + អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងជូនក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ពិធីសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការហាងកាហ្វេAmazon<br>- គណៈប្រតិភូព្រឹទ្ធសភា បានអញ្ជើញចូលរួមដង្ហែ និងពិធីបូជាព្រះសព **សម្តេច ស៊ីសុវត្ថិ ជីវ័នមុនីរ័ក្ស** អតីតអនុប្រធានទី១ ព្រឹទ្ធសភា ព្រមទាំងចូលរួមគោរពវិញ្ញាណក្ខន្ធសព ចំនួន០៤លើក<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានជួបសំណេះសំណាល បើកកិច្ចប្រជុំ វេទិកា និងសិក្ខាសាលា ពាក់ព័ន្ធនឹងមុខងាររបស់ខ្លួន ព្រមទាំងចូលរួមក្នុងពិធីផ្សេងៗចំនួន០៨លើក<br>- បានទទួលពាក្យបណ្តឹងចំនួន០៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នមានសមត្ថកិច្ចចំនួន ០១ករណី និងទទួលពាក្យបណ្តឹងជូនជ្រាប ១៥ករណី<br>- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានរៀបចំវេទិកាស្តីពី ការបូកសរុបលទ្ធផលការអនុវត្តផែនការអភិវឌ្ឍមូលដ្ឋាន ឃុំ- សង្កាត់ និងថ្នាក់ក្រោមជាតិ ធានានូវសុវត្ថិភាពមូលដ្ឋាន នៅព្រឹទ្ធសភា<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត រាជធានីទូទាំងប្រទេស ចំនួន២៤៨លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សា | - ទទួលឯកសារ សៀវភៅពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន ១១៨ក្បាល ព្រឹត្តិបត្រចំនួន៦៦ក្បាល ទស្សនាវដ្តីចំនួន១១៧ក្បាល ព្រះរាជក្រមចំនួន០៣ក្បាល និងកាសែតចំនួន១២ច្បាប់ ។ |

| | |
|---|---|
| ឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៧០លើក ។ | |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានអនុញ្ញាតឲ្យឯកអគ្គរាជទូតជប៉ុន ឯកអគ្គរដ្ឋទូតព័រទុយហ្គាល់ ប្រធានសមាគមមិត្តភាពសភាជប៉ុន-មេគង្គ ប្រធានក្រុមហ៊ុនសាងសង់ Anhui Foreign Construction ចូលជួបសម្តែងការគួរសម និងសវនាការ<br>- សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+អនុញ្ញាតឲ្យគណៈប្រតិភូខេត្តកនទុម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នាយកប្រតិបត្តិវិទ្យាស្ថានសន្ទនាមេគង្គ (MDI) និងនាយកសាលាហ្សាម៉ាន់(Zaman) ព្រមទាំងសហការីចូលជួបសម្តែងការគួរសម<br>+ជួបពិភាក្សាការងារជាមួយតំណាងក្រសួង | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អង្គទូត និងអង្គការអន្តរជាតិនានា<br>- ធ្វើពិព័រណ៍រូបភាព ផ្ទាំងប៉ាណូ បដា ពាក្យស្លោក និងធ្វើហ្វុងអក្សរក្នុងពិធីផ្សេងៗចំនួន០៤លើក<br>- ថត និងផ្សព្វផ្សាយសកម្មភាពគណៈប្រតិភូជាតិ អន្តរជាតិបំពេញទស្សនកិច្ចក្នុង និងក្រៅប្រទេសចំនួន១៩លើក<br>- រៀបចំសម្អាត តុបតែងសាល បម្រើ និងផ្តល់សេវាផ្គត់ផ្គង់សម្ភារៈ ភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន០៦លើក អ្នកចូលរួមចំនួន៦៤នាក់<br>- ផ្តល់សេវាថវិកាសម្រាប់ថ្នាក់ដឹកនាំព្រឹទ្ធសភា និង |

| | |
|---|---|
| រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានអង្គការCDF ប្រធានអង្គការសម្ព័ន្ធភាពអាស៊ី ប្រធាននាយកដ្ឋានសហប្រតិបត្តិការ និងកិច្ចការវប្បធម៌នៃស្ថានទូតបារាំងប្រចាំកម្ពុជា នាយកប្រតិបត្តិវិទ្យាស្ថានសភាកម្ពុជា (PIC)<br>- សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញទៅទស្សនកិច្ចសិក្សាឈ្វេងយល់អំពីការលូតលាស់ពាណិជ្ជកម្ម កសិកម្ម និងការគ្រប់គ្រងផ្ទៃឈើតំបន់ត្រូពិក នៅប្រទេសចិន ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី២៥ របស់វេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក(APPF) នៅសាធារណរដ្ឋហ្វីជី ចូលរួមប្រជុំក្រុមការងារកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់សភានិយាយភាសាបារាំង (APF) នៅប្រទេសប៊ែលហ្ស៊ិក ។ | មន្ត្រីរាជការចុះបេសកកម្ម ព្រមទាំងបានទូទាត់ថ្លៃចំណាយផ្សេងៗចំនួន២២លើក<br>- ផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងរាជធានីភ្នំពេញចំនួន៥០នាក់ ស្មើនឹង០៩លើក<br>- ទំនាក់ទំនងជាមួយស្ថានទូតបណ្តាប្រទេសជាមិត្ត ដើម្បីសម្រួលបែបបទ និងកម្មវិធីទស្សនកិច្ច ធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូត និងជំនួយស្មារតី សុំទិដ្ឋាការ រៀបចំបែបបទបើកបន្ទប់ពិសេស (VIP) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ជូននិងទទួលដំណើរបេសកកម្មសរុបចំនួន១៥លើក<br>- ចេញលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៦នាក់ ស្មើនឹង០២ច្បាប់ និងបញ្ជូនលិខិតទៅក្រៅស្ថាប័នព្រឹទ្ធសភាចំនួន៨៣ច្បាប់<br>- រៀបចំកញ្ចប់ថវិកាដំណើរបេសកកម្មជូនថ្នាក់ដឹកនាំនិងសមាជិក សមាជិកាព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន០៣លើក<br>- ការពារសន្តិសុខ សុវត្ថិភាព រៀបចំសណ្តាប់ធ្នាប់ ដោយប្រើប្រាស់កម្លាំងសរុបចំនួន៦៧នាក់ ស្មើនឹង០៥លើក<br>- អគ្គលេខាធិការបានជួបពិភាក្សាការងារជាមួយ ប្រធានវិទ្យាស្ថានបារាំង ប្រធានអង្គការមូលនិធិ Max Planck អនុប្រធានបេសកកម្មការទូត |

| | |
|---|---|
| | នៃសាធារណរដ្ឋប៉ូឡូញ រុស្សី ព្រមទាំងចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសមាគមអគ្គលេខាធិការសភាប្រើប្រាស់ភាសាបារាំង (ASGPF) នៅប្រទេសបារាំង<br>- ទំនាក់ទំនងជាមួយស្ថានទូតបារាំង សភាវ៉ាឡូនីព្រុចសែល ប៊ែលហ្ស៊ិក ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង សមាគមអគ្គលេខាធិការនិយាយភាសាបារាំង សង្គមស៊ីវិល ក្រសួង និងស្ថាប័ននានា សម្រាប់ដំណើរទស្សនកិច្ច សិក្ខាសាលា និងបំពេញបេសកកម្មក្នុងនិងក្រៅប្រទេស ស្នើសុំអាហារូបករណ៍វគ្គបណ្តុះបណ្តាល និងការរៀបចំពិធីផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - រៀបចំបែបបទ សុំជំនួយពីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីសាងសង់សាលប្រជុំពេញអង្គថ្មី<br>- កិច្ចសហប្រតិបត្តិការជាមួយដៃគូរ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន។ | - ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៦៣៩ច្បាប់<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៧០ច្បាប់<br>- ប្រជុំគណៈកម្មការរៀបចំ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំអន្តរគណៈកម្មការពិនិត្យ និងកែសម្រួលសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ និងបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំគណៈកម្មការស្តីពី ការគ្រប់គ្រងមន្ត្រីរាជការ |

| | |
|---|---|
| | នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលសិក្សាក្នុងប្រទេស និងការគ្រប់គ្រងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ប្រជុំសិក្សា និងរៀបចំសមាហរណកម្មក្របខ័ណ្ឌបច្ចុប្បន្នរបស់មន្ត្រីរាជការទៅក្នុងក្របខ័ណ្ឌឋានន្តរស័ក្តិ និងថ្នាក់ថ្មី<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស:<br>- ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុង និងក្រៅប្រទេសសរុបចំនួន០៣វគ្គ មានសិក្ខាកាមចូលរួមចំនួន១៣នាក់<br>- បន្តអនុវត្តកម្មវិធីកម្មសិក្សាពីនិស្សិតក្នុងប្រទេស និងក្រៅប្រទេស<br>+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:<br>- រៀបចំតម្លើងសន្ទស្សន៍បៀវត្សពី១៧០០រៀល ទៅ១៩០០រៀល និងការកែសម្រួលប្រាក់មូលដ្ឋានគិតពន្ធលើប្រាក់បៀវត្សរបស់មន្ត្រីរាជការ<br>- ប្រជុំក្រុមការងារបច្ចេកទេសថវិកា<br>- រៀបចំធ្វើរបាយការណ៍ចំណូល ចំណាយថវិកាព្រឹទ្ធសភាឆ្នាំ២០១៦ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងការបែងចែកថវិការបស់ព្រឹទ្ធសភា ប្រចាំឆ្នាំ២០១៧<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់រំភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែមករា ឆ្នាំ២០១៧ ផ្ញើជូនក្រសួងសេដ្ឋកិច្ច |

| | |
|---|---|
| | និងហិរញ្ញវត្ថុ<br>- ទូទាត់ថ្លៃទិញសម្ភារៈ គ្រឿងអេឡិចត្រូនិច ជួសជុលសម្ភារៈឧបករណ៍បច្ចេកទេសផ្សេងៗ ជួសជុលរថយន្ត ជួសជុលហេដ្ឋារចនាសម្ព័ន្ធ កែលម្អសោភ័ណ្ឌភាពបរិក្ខារផ្សេងៗនៅក្នុងបរិវេណព្រឹទ្ធសភា<br>- បានលើកគម្រោងទិញវត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំ និងសិក្ខាសាលាចំនួន១៨សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ ការិយាល័យ និងភេសជ្ជៈចំនួន៥៧សំណើ ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- រៀបចំសម្អាត តុបតែងសាល និងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងពិធីផ្សេងៗចំនួន២១លើក មានអ្នកចូលរួមចំនួន៨៨១នាក់<br>- ផ្តល់សេវាថវិកាសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងទូទាត់ថ្លៃចំណាយផ្សេងៗចំនួន៧៤លើក<br>- ថតចម្លងឯកសារ និងរៀបចំចងក្រងធ្វើជាសៀវភៅចំនួន៩៩ក្បាល អស់ក្រដាសចំនួន៣៩,៧៤៧សន្លឹក ព្រមទាំងផ្តល់សេវាដឹកជញ្ជូនទៅតាមបណ្តាលខេត្ត ក្រុងទាំង៨ភូមិភាគ និងក្នុងរាជធានីភ្នំពេញចំនួន៦១៥នាក់ ស្មើនឹង២២៧លើក<br>**+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រឹង និងទន់:**<br>- សិក្សាប្លង់អគារសាលប្រជុំពេញអង្គចាស់ និងថ្មី |

| | |
|---|---|
| | - តាមដានគម្រោងស្នើសុំសាងសង់អគារសាលប្រជុំពេញអង្គថ្មី ជាមួយស្ថាប័នពាក់ព័ន្ធ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថានទូតចិន)<br>- ចាត់ចែង និងរៀបចំពិធីសម្ពោធអគារការិយាល័យថ្មីរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា<br>- រៀបចំហេដ្ឋារចនាសម្ព័ន្ធនានា នៅជុំវិញអគារការិយាល័យថ្មីរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងបំពាក់អំពូលហ្វា LED តបណ្តាញអគ្គីសនីទូរទស្សន៍ខ្សែកាប្លិ<br>- រៀបចំសុំគោលការណ៍ ដើម្បីត្រៀមរៀបចំជួសជុលអគារសាលប្រជុំពេញអង្គចាស់ និងរៀបចំគម្រោងស្នើសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤ព្រឹទ្ធសភា<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភាឲ្យមានសោភ័ណ្ឌភាពល្អ<br>- ជួសជុល និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិចចំនួន១២៥គ្រឿង បណ្តាញទឹកចំនួន០៤បន្ទប់/ខ្សែ<br>- បិទលេខកូដម៉ាស៊ីនព្រីនធ័រ ម៉ាស៊ីនហ្វូតូកូពី ម៉ាស៊ីនបោកព្រុំ ម៉ាស៊ីនសម្ងួត ម៉ាស៊ីនជូតម៉ាបទូរស័ព្ទ តុ ទូ កៅអី អំភ្លី និងម៉េក្រូហ្វូនចំនួន៩៦គ្រឿង<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួន២៧គ្រឿង ។ រៀបចំមាតិកា និងUpload |

| | |
|---|---|
| | របកភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន ១៦៣ចំណងជើង<br>+ការងារផ្សេងៗ:<br>- ថត និងផ្សព្វផ្សាយទស្សនាវដ្ដី និងព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន១៥៩ លើក<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្ដី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និងបញ្ចូលសៀវភៅតាម PMB E-Library បណ្ដាញ Facebook សរុបចំនួន៤,០៦១ក្បាល ។ |

II.**ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០១៧**

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣

-ត្រៀមបន្តនីតិវិធីពាក់ព័ន្ធច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាក់តែង និងពិគ្រោះយោបល់អំពីសេចក្តីព្រាងក្រមសីលធម៌ សមាជិកព្រឹទ្ធសភា និងបទបញ្ជាផ្ទៃក្នុងថ្មី ។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្ដាខេត្ត-ក្រុង ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្ដាខេត្ត-ក្រុង ជាពិសេសកម្មវិធីសម្ពោធសមិទ្ធផលនានានៅវត្តចំនួន០២ ក្នុងខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា ។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា ព្រមទាំងពិធីទទួលសារតាំងទូតថ្មី

+ពិធីបដិសណ្ឋារកិច្ចគណៈប្រតិភូជាន់ខ្ពស់រុស្ស៊ី ព្រឹទ្ធសភាបារាំង និងសភា Wallonie Bruxelles

+ត្រៀមការចុះហត្ថលេខារវាងលេខាធិការដ្ឋាន(APF) និងវិទ្យាស្ថានសភាកម្ពុជា (PIC) និងកម្មវិធីបណ្តុះបណ្តាលពីចំងាយរបស់លេខាធិកាដ្ឋាន(APF)

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា៖ ASGPF, SES, CIM, KAS, GIZ, MAX PLANCK FOUNDATION, UNESCO, JICA និង KOICA

-ត្រៀមរៀបចំគម្រោងសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី៤

-រៀបចំការបណ្តុះបណ្តាល PBO អ្នកស្រាវជ្រាវខាងទំនាក់ទំនងអន្តរជាតិ និងទំនាក់ទំនងលេខាធិការដ្ឋាន (APF) អំពីសហប្រតិបត្តិការបច្ចេកទេស

-សហប្រតិបត្តិការតំបន់ (ត្បូង-ត្បូង) តាមរយៈកម្មវិធីបណ្តុះបណ្តាលខាងការស្រាវជ្រាវ និងការអនុវត្ត MOU សហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវសភា ឥណ្ឌា និងប៉ាគីស្ថាន (ទ្រឹស្តី Domino)។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

- បន្តរៀបចំជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារៈប្រើប្រាស់៖ការជួសជុលដំបូល និងជញ្ជាំងអគារក្រហម ការជួសជុលផ្នែកស្វាបឆ្វេង និងស្វាបស្តាំអគារក្រហម រៀបចំដូរកម្រាលព្រំនៅអគារក្រហមមានបន្ទប់ទទួលភ្ញៀវ បន្ទប់រង់ចាំ បន្ទប់គណៈកម្មាធិការអចិន្ត្រៃយ៍ និងបន្ទប់ឆ្វេងកាត់កណ្តាល ព្រមទាំងរៀបចំគូសគំនូសចំណតរថយន្ត និងសញ្ញាបង្ហាញផ្លូវ

-សិក្សាប្លង់អគារសាលប្រជុំពេញអង្គចាស់ និងថ្មី

-បង្កើតការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការគ្រប់គ្រងការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះចូលអនុវត្តកម្មវិធី E បណ្ណាល័យ និងE បណ្ណសារ

-បន្តប្រជុំអន្តរគណៈកម្មការកែសម្រួលច្បាប់លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

-បន្តប្រជុំគណៈកម្មការពិនិត្យ និងកែសម្រួលបទបញ្ជាផ្ទៃក្នុងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធតួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំគណៈកម្មការរៀបចំធ្វើសមាហរណកម្មមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលក្នុងក្របខ័ណ្ឌថ្មី

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-បន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ជប៉ុន ឥណ្ឌា និងការបំពាក់សម្ភារបរិក្ខារៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជំនួយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍តាមប្រភពពីកូរ៉េ ជប៉ុន ចិន អូស្ត្រាលី នូវែលហ្សេឡង់ ឥណ្ឌា សិង្ហបុរី ម៉ាឡេស៊ី និងថៃ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធនធានមនុស្ស

-រៀបចំផែនការប្រតិបត្តិឆ្នាំ២០១៧ បច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ១០ឆ្នាំ រៀបចំផែនការថវិកាតាមកម្មវិធីសម្រាប់ឆ្នាំ២០១៧ បច្ចុប្បន្នភាពលើមូលដ្ឋានគោលការណ៍ 3E's ទ្រព្យសម្បត្តិ ធនធានមនុស្ស និងតម្រូវការ ។

**III.សេចក្តីសន្និដ្ឋាន**

ខែមករានេះ ជាខែដើមឆ្នាំ២០១៧ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានការងារមមាញឹកច្រើនលើគ្រប់ការដ្ឋាន ដើម្បីបញ្ចប់ការងារដែលសេសសល់ពីឆ្នាំ២០១៦ ។ ម្យ៉ាងទៀតនេះជាជំហានដំបូងដើមឆ្នាំ សម្រាប់អនុវត្តផែនការប្រតិបត្តិឆ្នាំ២០១៧ តាមក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភា ។ អគ្គលេខាធិការដ្ឋានបានយកចិត្តទុកដាក់ខ្ពស់លើការកែសម្រួលសន្ទស្សន៍ប្រាក់បៀវត្សថ្មី និងការកែសម្រួលប្រាក់ពន្ធលើបៀវត្ស នេះជាដំណឹងល្អសម្រាប់មន្ត្រីរាជការដែលទទួលបានផលប្រយោជន៍បន្ថែម រួមការពិចារណាអំពីបច្ចុប្បន្នកម្មលើច្បាប់ លិខិតបទដ្ឋានផ្សេងៗ ។ ជាមួយគ្នានេះ បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម បានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភាចំនួន០១លើក។ ចំពោះមុខងារតំណាង បានចាត់ចែងកម្មវិធីចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ ព្រមទាំងចូលរួមគោរពវិញ្ញាណក្ខន្ធសព និងពិធីផ្សេងៗទៀត នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ព្រៃវែង កំពង់ចាម ត្បូងឃ្មុំ កែប សៀមរាប បាត់ដំបង និងខេត្តប៉ៃលិន ។ ការអភិវឌ្ឍស្ថាប័នបានឆ្លុះបញ្ចាំងឲ្យឃើញនូវការអភិវឌ្ឍធនធានមនុស្ស ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ការកសាងអគារ និងហេដ្ឋារចនាសម្ព័ន្ធមានការរីកចម្រើន ជាពិសេសសមិទ្ធផលថ្មីមួយ អគារការិយាល័យថ្មីរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ដែលជាកាដូសម្រាប់ដើមឆ្នាំថ្មី ត្រូវដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការ ។ ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិបានបន្តយុទ្ធនាការស្វែងរក

ការគាំទ្រ និងជំនួយពីប្រកពក្នុង និងក្រៅប្រទេសសម្រាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា ( PIC ) ដៃគូអភិវឌ្ឍន៍ និងប្រទេសជាមិត្តនានា ។ កិច្ចការជាអាទិភាពក្នុងឆ្នាំ២០១៧នេះគឺៈ

១-បញ្ចប់ដោយជោគជ័យនូវនីតិកាលទី៣ ព្រឹទ្ធសភា

២-ចាប់ផ្តើមដោយរលូននូវនីតិកាលទី៤ព្រឹទ្ធសភា ប្រការនេះទាមទារឲ្យធ្វើការផាពហុវិស័យ និងត្រៀមបំរុងជាមុនដោយសព្វគ្រប់នូវគ្រប់ការដ្ឋានសំខាន់ៗ ។៚

ភ្នំពេញ, ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ